មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ គីម ធី ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ«យោធានិរសា»

## ស្រុកកំណើតនៅភូមិក្បាលកោះ ឃុំ.... ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

## រស់នៅភូមិសែនសំ ឃុំអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:៣៨:០០

## ១៥ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់ណែនាំខ្លួនខ្ញុំផ្ទាល់ពូ ខ្ញុំឈ្មោះ សោម ប៊ុនថន ។

ធីៈ ឈ្មោះអី.

ប៊ុនថនៈ សោម ប៊ុនថន ។

ធីៈ សោម ប៊ុន ។

ប៊ុនថនៈ បាទ!មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំអនុញ្ញាតសម្ភាសលោកពូ?

ធីៈ បាទ ។

ប៊ុនថនៈ ចឹងខ្ញុំកត់ត្រាចូលក្នុងសៀវភៅ ដោយសារខ្ញុំកត់ត្រាមិនទាន់ខ្ញុំ ខ្ញុំសូមថតជាសម្លេងដើម្បីស្តាប់លោកពូ?

ធីៈ បាទ ។

ប៊ុនថនៈ ចឹងពូអនុញ្ញាតឲ្យខ្ញុំសម្ភាសទេ?

ធីៈ បាទ ។

ប៊ុនថនៈ ចឹងដំបូងខ្ញុំសុំសួរឈ្មោះពូ ពូឈ្មោះអីដែរ?

ធីៈ គីម ធី ។

ប៊ុនថនៈ ពូអាយុប៉ុន្មាន?

ធីៈ អាយុ៥៨ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ធីៈ ស្រុកកំណើតនៅភូមិក្បាលកោះ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។

ប៊ុនថនៈ សព្វថ្ងៃរស់នៅភូមិឃុំអីដែរ?

ធីៈ សព្វថ្ងៃនៅឃុំអូរស្មាច់ ភូមិសែនសំ ។

ប៊ុនថនៈ ស្រុក?

ធី៖ ត្រពាំងប្រាសាទ ។

ប៊ុនថន៖ ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ធី៖ ខ្ញុំអត់មានទេ នៅកន្លែងនេះ ។

ប៊ុនថន៖ បងប្អូនបង្កើត?

ធី៖ បាទ!អត់មានទេ ។

ប៊ុនថន៖ ចឹងពូមានម្នាក់ឯងទេ?

ធី៖ ម្នាក់ឯងទេ ទោលសុទ្ធ មានតែបងប្អូនខាងប្រពន្ធ ។

ប៊ុនថន៖ បាទ!ឪពុកម្ដាយពូមាននៅរស់ទេ?

ធី៖ ស្លាប់អស់ហើយ ។

ប៊ុនថន៖ ឪពុកពូឈ្មោះអី?

ធី៖ ឪពុកឈ្មោះ យឹម ។

ប៊ុនថន៖ គីម យឹម?

ធី៖ អត់ទេ យកឈ្មោះខ្ញុំដាក់គីម ខ្ញុំធី ក៏ប៉ុន្តែឈ្មោះឪពុកហ្នឹងឈ្មោះតាយឹម ។

ប៊ុនថន៖ ចឹងគាត់មានត្រកូលគាត់ទេ?

ធី៖ អត់ដឹងផង ។

ប៊ុនថន៖ គាត់ស្លាប់ជំនាន់ណា?

ធី៖ ជំនាន់អាពត ។

ប៊ុនថន៖ ចឹងម្ដាយ?

ធី៖ ឈ្មោះ យ៉ែម វុន ។

ប៊ុនថន៖ គាត់នៅរស់ទេ?

ធី៖ ថា អស់ហើយ ។

ប៊ុនថន៖ ស្លាប់ជំនាន់ណាដែរ?

ធី៖ ជាមួយគ្នាហ្នឹង ប្រហែលជាមួយឆ្នាំម្ដង ។

ប៊ុនថន៖ ពូកាលពីតូចបានរៀនសូត្រដល់ត្រឹមណាដែរ?

ធី៖ កាលពីតូចខ្ញុំរៀនបានត្រឹមថ្នាក់ទី៨ អេះ!ទី៩ ។

ប៊ុនថន៖ ចឹងថ្នាក់ទី៩ចាស់?

ធី៖ បាទ ។

ប៊ុនថន៖ រៀននៅសាលាណាពូ?

ធី: កាលនោះរៀននៅសាលាស្អីទេ ភ្លេចសាលាទៀត រៀននៅផ្ទះគ្រូ អ៊ុន តែម្តង គ្រូអេន ផង កាលហ្នឹង យល់ហើយប៉ុណ្ណឹង ។

ប៊ុនថន: បាទ! លោកឈប់រៀននៅឆ្នាំណា?

ធី: រដ្ឋប្រហាររួច គេកំពង់តែរដ្ឋប្រហារឈប់រៀនបណ្តោយ ។

ប៊ុនថន: រដ្ឋប្រហារឆ្នាំ៧០?

ធី: បាទ ។

ប៊ុនថន: ទម្លាក់សម្តេចឪ?

ធី: ហ្នឹងហើយណា រដ្ឋប្រហារឈប់រៀន ។

ប៊ុនថន: ចឹងបន្ទាប់ពីឈប់រៀនពូធ្វើអី?

ធី: អត់មានធ្វើអីទេ ។

ប៊ុនថន: នៅជាមួយឪពុកម្តាយ?

ធី: នៅជាមួយឪពុកម្តាយ រកដាក់ទ្រូដាក់លប ពេញហ្នឹងឯង ។

ប៊ុនថន: កាលហ្នឹងឪពុកម្តាយពូធ្វើអីដែរ?

ធី: ឪពុកខ្ញុំកាលហ្នឹងនិយាយទៅវាវែងឆ្ងាយពេក គាត់ពីដើមមកគាត់ធ្វើទាហានអាមេរិច ក៏ប៉ុន្តែត្រឡប់មកវិញ គេរករឿងគាត់ រករឿងគាត់គេឲ្យបើកឡានមួយថ្ងៃៗមួយយប់ទាល់ភ្លឺចង់ងាប់ហើយ ។

ប៊ុនថន: គេឲ្យបើកឡានខាងណាវិញ?

ធី: បើកឡានកាលជំនាន់ អាពត នោះ ។

ប៊ុនថន: គាត់ចូលខាងបដិវត្តដែរ?

ធី: បាទ! បើកឡានដឹកជំឡូងដឹកអីឲ្យគេកងចល័តគេនោះ កាលហ្នឹងមានកងចល័តគេ ។

ប៊ុនថន: ចឹងម្តាយ?

ធី: ម្តាយខ្ញុំអត់មានទៅណាផង នៅផ្ទះ ។

ប៊ុនថន: ពូនៅជាមួយឪពុកម្តាយដល់ឆ្នាំណាបានពូចូលបដិវត្ត?

ធី: អត់ទេ ចូលនៅជាមួយឪពុកម្តាយហ្នឹងហើយតើ អស់!ដកចេញពីឪពុកម្តាយ ។

ប៊ុនថន: ចេញចូលធ្វើបដិវត្ត?

ធី: ចេញឆ្នាំ៧៧ ។

ប៊ុនថន: ចឹងពូថា៧៥នោះ មុនបែកភ្នំពេញនោះ?

ធី: អត់ទេ មើលបែកភ្នំពេញនោះ៧៥មែនហើយ ដកចេញពីម៉ែឪឈប់នៅជាមួយគាត់ ។

ប៊ុនថន៖ បាទ!ចឹង៧៤?

ធី៖ ៧៤ ។

ប៊ុនថន៖ មានចាំខែទេ?

ធី៖ អត់ទេ ។

ប៊ុនថន៖ ចឹងតែឆ្នាំ?

ធី៖ ដឹងតែឆ្នាំ ។

ប៊ុនថន៖ ៧៤ហ្នឹងពូចេញទៅខាងណាវិញ?

ធី៖ ចេញមកកតស៊ូទៅ ។

ប៊ុនថន៖ ចេញមកកតស៊ូ?

ធី៖ បាទ ។

ប៊ុនថន៖ ពីណាអ្នកនាំចូលកាលហ្នឹង?

ធី៖ តាម៉ុន ។

ប៊ុនថន៖ តាម៉ុន គាត់ធ្វើអីដែរ?

ធី៖ កាលហ្នឹងគេហៅគាត់អង្គការ ប្រធានអង្គការ ។

ប៊ុនថន៖ ឈ្មោះ ម៉ុន?

ធី៖ ដាក់ឈ្មោះ ម៉ុនថា ។

ប៊ុនថន៖ បន្ទាប់ពីចូលហើយពូទៅណាទៀត?

ធី៖ អត់មានទៅណាអត់ទេ មានតែមកចេះហើយ ។

ប៊ុនថន៖ ពូចូលហើយមានហាត់ទេ?

ធី៖ អត់ទេ ។

ប៊ុនថន៖ ចឹងពូធ្វើកិច្ចការអីវិញ ពេលចូលជាមួយអង្គការហ្នឹង?

ធី៖ ថាខ្ញុំចូលជាមួយអង្គការហ្នឹង កាលសម័យប៉ុល ពត ហ្នឹងខ្ញុំចូលទៅខ្ញុំនៅក្រុមនិរសាគេទេ និរសាគេ មើលទឹកត្រជាក់ទឹកក្ដៅឲ្យគេតែប៉ុណ្ណឹង ។

ប៊ុនថន៖ ចឹងធ្វើនិរសា?

ធី៖ បាទ!ឥឡូវគេហៅអង្គរក្ស នៅអង្គរក្សតាម៉ុន ។

ប៊ុនថន៖ និរសាហ្នឹងយើងធ្វើអីខ្លះទៅ?

ធី៖ ដាំទឹកឲ្យគេ ដាំបាយឲ្យគេហូបទៅ ។

ប៊ុនថន៖ ចឹងមានរត់សំបុត្រអីទេ?

ធី៖ អត់ទេ ។

ប៊ុនថន៖ ចឹងតែដាំបាយដាំទឹកទេ?

ធី៖ បាទ!អត់មានរត់សំបុត្ររត់អីណាទេ ។

ប៊ុនថន៖ កាលហ្នឹងតាម៉ុន ហ្នឹងគាត់នៅណាពូ ដូចថានៅក្រចេះ អ!នៅស្ទឹងត្រែង?

ធី៖ តាម៉ុន នៅភ្នំពេញ នៅអគ្គស្ថួលបែកចាន ។

ប៊ុនថន៖ ចឹងពេលចូលជាមួយគាត់ហ្នឹង ពូចូលមកនៅខាងអគ្គស្ថួល?

ធី៖ បាទ ។

ប៊ុនថន៖ ចឹងពូអត់មាននៅភូមិឃុំខាងថាឡាបរិវ៉ាត់ទេ?

ធី៖ អាហ្នឹងស្រុកខ្ញុំភូមិខ្ញុំតើ ។

ប៊ុនថន៖ ចឹងពូនិរសាហ្នឹងពូចូលមកនៅជាមួយតាម៉ុន តែម្ដង?

ធី៖ បាទ!ជំបូងខ្ញុំនៅនិរសាក្រុង រួចគាត់ទៅយកខ្ញុំមក ទៅយកខ្ញុំពីនិរសាក្រុងមកឲ្យធ្វើនិរសាគាត់ម្ដង ។

ប៊ុនថន៖ ចឹងមុនពូនិរសាក្រុងទេ?

ធី៖ បាទ ។

ប៊ុនថន៖ និរសាក្រុងភ្នំពេញ?

ធី៖ ភ្នំពេញ ។

ប៊ុនថន៖ ចុះមុនពេលបែកពូនៅណា មុនបែក៧៥ ?

ធី៖ ខ្ញុំនៅផ្ទះ ។

ប៊ុនថន៖ នៅផ្ទះ?

ធី៖ នៅផ្ទះ ។

ប៊ុនថន៖ តែក្រែងពូចូលនៅឆ្នាំ៧៤ ចូលមកខាងបដិវត្ត៧៤?

ធី៖ បាទ ។

ប៊ុនថន៖ ចឹង៧៤ហ្នឹងពូនៅខាងស្ទឹងត្រែងឬពូមកនៅខាងណាវិញ?

ធី៖ ថានៅស្ទឹងត្រែងនៅជាមួយម៉ែឪចេះណា អត់មានទៅណាទេ ។

ប៊ុនថន៖ ចឹងឆ្នាំ៧៤ពូចូលមកនៅជាមួយតាម៉ុន មកខាងបែកចានភ្នំពេញ?

ធី៖ បាទ ។

ប៊ុនថន៖ ហើយដល់ពេលវាយឈ្នះភ្នំពេញឆ្នាំ៧៥ ពូចូលក្នុងនិរសាក្រុង?

ធី៖ បាទ ។

ប៊ុនថន៖ ចូលនិរសាក្រុងភ្នំពេញ?

ធី៖ មួយឆ្នាំ ។

ប៊ុនថន៖ មួយឆ្នាំ?

ធី៖ បាទ!រួចតាម៉ុន ទៅយកខ្ញុំមក ។

ប៊ុនថន៖ យកពូពីភ្នំពេញហ្នឹង?

ធី៖ មកនៅជានិរសាគាត់ ។

ប៊ុនថន៖ មកនៅជានិរសាគាត់វិញ?

ធី៖ បាទ ។

ប៊ុនថន៖ នៅហើយបានពូចេញទៅខាងស៊ីងត្រែងវិញ?

ធី៖ បាទ ។

ប៊ុនថន៖ ចឹងពូទៅស៊ីងត្រែងជាមួយតាម៉ុន ហ្នឹងទាំងកងតែម្ដង?

ធី៖ អត់ទេ អត់មានទៅទាំងកងទេ ទៅអង្គរក្សគាត់មានបីបួននាក់ហ្នឹង ទាំងខ្ញុំទាំងអស់ហ្នឹង ។

ប៊ុនថន៖ នៅផ្ទាល់ជាមួយគាត់តែម្ដង?

ធី៖ បាទៗ!នៅផ្ទាល់ជាមួយគាត់ ។

ប៊ុនថន៖ កាលហ្នឹងគាត់នៅកងប៉ុន្មាន តាម៉ុន?

ធី៖ តាម៉ុន នោះ លេខ៨០១ដូចគ្នា ។

ប៊ុនថន៖ តែកងវរសេនាធំលេខប៉ុន្មាន?

ធី៖ លេខ៥ ។

ប៊ុនថន៖ កងវរសេនាធំលេខ៥?

ធី៖ បាទ ។

ប៊ុនថន៖ កាលហ្នឹងឈរជើងនៅម្ដុំណា កងវរសេនាធំលេខ៥របស់គាត់?

ធី៖ ឈរជើងនៅកំពង់ធំ ។

ប៊ុនថន៖ កំពង់ធំ?

ធី៖ បាទ ។

ប៊ុនថន៖ កំពង់ធំនៅម្ដុំណា?

ធី៖ នៅម្ដុំស្រុកភ្នំសន្ទុក នៅម្ដុំហ្នឹង ភ្នំសន្ទុកម្ដុំព្រៃឡង់ព្រៃអីហ្នឹង ខ្ញុំច្បាស់ណាស់ខ្ញុំ ។

ប៊ុនថន៖ ពូនៅជាមួយគាត់បានប៉ុន្មានឆ្នាំ?

ធី៖ នៅមួយឆ្នាំជាមួយគាត់ ដល់ខ្ញុំរស់នៅជាមួយគាត់មួយឆ្នាំក៏ខ្ញុំមានឋានៈតំណែង ខ្ញុំឡើងកាន់មេដៃរ មេខ្មែរក្រហម ។

ប៊ុនថន៖ គេហៅមេអីវិញ?

ធី៖ មេកងវរៈ ។

ប៊ុនថន៖ វរៈលេខប៉ុន្មាន?

ធី៖ វរៈលេខ៨០ ។

ប៊ុនថន៖ វរសេនាតូច?

ធី៖ វរសេនាតូច ។

ប៊ុនថន៖ ឆ្នាំប៉ុន្មានពូឡើងវរៈ?

ធី៖ ឆ្នាំប៉ុន្មានទេ មើល៨៥ឬ៨០ប៉ុន្មានទេ ។

ប៊ុនថន៖ វៀតណាមវាយចូលហើយ?

ធី៖ វាយចូលរួចអស់ហើយ បានវាយចូលហើយបានខ្ញុំខ្លាំងហ្នឹងណាស់ ខ្ញុំខ្លាំងដែលបានខ្ញុំឡើង បើមិនខ្លាំងគេមិនឲ្យឡើងទេ ។

ប៊ុនថន៖ ចឹងក្រោយវៀតណាមវាយប៉ុន្មានឆ្នាំបានពូឡើងវរៈ?

ធី៖ ពីរឆ្នាំ ។

ប៊ុនថន៖ មើល៧៩-៨០ ចឹងពូឡើងឆ្នាំ៨២ចឹង?

ធី៖ ខ្ញុំឡើងឆ្នាំ៨៣ ។

ប៊ុនថន៖ ចឹងកាលពីមុនហ្នឹងពូជានិរសាទេ?

ធី៖ បាទ!ជានិរសាទេ ឧទាហរណ៍ដូចប្អូនចឹង ប្អូនមេចឹងខ្ញុំទៅធ្វើអង្គរក្សឲ្យធ្វើនិរសាឲ្យប្អូនចេះណាស់ ។

ប៊ុនថន៖ បាទ ។

ធី៖ បើចឹងគាត់អាណិតអាសូរ្យ គាត់ដកចេញទៅឲ្យឡើងទៅចេះ ។

ប៊ុនថន៖ ចឹងកាលពូធ្វើនិរសាឲ្យគាត់ទៅតាមគាត់ដល់ណាខ្លះពូ?

ធី៖ អត់មានទៅដល់ណាទេ នៅហ្នឹងខ្មែរក្រហមហ្នឹង ។

ប៊ុនថន៖ តែទៅប្រចាំខេត្តណាខ្លះពូ?

ធី៖ នៅកំពង់ចាម ។

ប៊ុនថន៖ នៅខេត្តណាទៀត?

ធី៖ កំពង់ចាម ក្រចេះ សៀមរាបអត់ទេ កំពង់ចាម ក្រចេះ កំពង់ធំ បីខេត្តហ្នឹង ។

ប៊ុនថន: ចឹងពូទៅតាមគាត់បីខេត្តហ្នឹង?

ធី: បាទ ។

ប៊ុនថន: ចឹងរហូតដល់ឆ្នាំ៨៣បានពូឡើងប្រធានវរសេនាតូច?

ធី: បាទ ។

ប៊ុនថន: វរសេនាតូចហ្នឹងក្តាប់គ្នាប៉ុន្មាននាក់ កូនចៅ?

ធី: វរសេនាតូចមានកូនចៅ១០០ជាងនោះ ។

ប៊ុនថន: ចឹងវរសេនាតូច១០០ជាង?

ធី: បាទ ។

ប៊ុនថន: ចឹងពីកាន់វរសេនាតូចហ្នឹងពូដឹកនាំវាយនៅណាខ្លះទៅ?

ធី: ខ្ញុំហ្នឹងអត់មានវាយកន្លែងណាទេ វាយនៅខាងទន្លេសាបវាយខាងជើងទឹក ។

ប៊ុនថន: វាយខាងជើងទឹកវិញ?

ធី: បាទ! ជើងទឹកដាក់ត្រឹបបណ្តោយ ។

ប៊ុនថន: កាលហ្នឹងមានទូកមានកប៉ាល់អីទេ?

ធី: មានម៉ាស៊ីនដាក់ ។

ប៊ុនថន: វាយយ៉ាងម៉េចអាចប្រាប់ខ្ញុំបានទេ របៀបវាយរបៀបភូមិសាស្រ្តអី?

ធី: ដូចនេះទូកគេចាប់កាំភ្លើងនេះទៅ ខាងនេះដាក់៦០មួយទៅ ហើយបាញ់ទៅទ្រឹតៗៗៗដាក់ទៅភ្នូកក្រាំង ។

ប៊ុនថន: ចឹងយើងចាប់កាំភ្លើងនៅលើទូកហ្នឹងយើងបាញ់?

ធី: បាទ! លើទូកមានម៉ាស៊ីន ។

ប៊ុនថន: បាញ់ហ្នឹងខាងពូមានគ្រោះថ្នាក់អីទេ?

ធី: អត់ទេ អត់ដែលទេ ផាប់មួយទូកអស់ហើយ ផាប់មួយទូកហើយ ទូកតាសំ តាសំមេវរសេនាធំទៀត ។

ប៊ុនថន: ឈ្មោះ អី សំត្រកូលគាត់?

ធី: អត់ទេ អត់ដឹងផង ។

ប៊ុនថន: វរសេនាធំលេខ៥ហ្នឹងឬលេខប៉ុន្មាន?

ធី: គាត់នៅខាង៧/៨៥នោះទេ ជាមួយតាតេម ។

ប៊ុនថន: តាតេម?

ធី: បាទ! ស្គាល់តាតេមដែរ ។

ប៊ុនថន: តាគេមខ្ញុំប្ដូរឈ្មោះគាត់តើ ។

ធី: តាគេម គាត់នៅ៧៨៥ហ្នឹង ។

ប៊ុនថន: បាទ!៧៨៥ ។

ធី: តាសំ នៅជាមួយតាសំ ឈ្លួសជាមួយប៉ូលិស ។

ប៊ុនថន: គេបាញ់ត្រូវ?

ធី: គេបាញ់ត្រូវ ។

ប៊ុនថន: ពេលពូឡើងទៅវាយហ្នឹងនៅសមរភូមិណាខ្លះ ពេលនៅវាយនៅទន្លេសាបហ្នឹងនៅសមរភូមិណាខ្លះពូ ពូមានចាំទេ?

ធី: វាយពេញតែហ្នឹងឯង ។

ប៊ុនថន: នៅម្ដុំណាខ្លះពីអាចរៀបរាប់បានទេ ពូអាចប្រាប់ទីកន្លែង?

ធី: នៅកំពង់ធំអីហ្នឹង ។

ប៊ុនថន: កំពង់នៅណាខ្លះ?

ធី: មិនចេះប្រាប់ទេ ពេញតែហ្នឹងឯង ។

ប៊ុនថន: នៅតែក្នុងខេត្តកំពង់ធំទេ?

ធី: បាទ ។

ប៊ុនថន: តាមទន្លេ?

ធី: បាទ!លើគោកក៏លើគោកទឹកក៏ទឹក ។

ប៊ុនថន: ពូចេះហែលទឹកដែរ?

ធី: ខ្ញុំមិនចេះអួតទេ អត់អួតទេរឿងទឹក ។

ប៊ុនថន: ពូនៅហ្នឹងដល់ឆ្នាំណា នៅខាងទន្លេសាបហ្នឹងដល់ឆ្នាំណាបានពូផ្លូចេញពីហ្នឹង?

ធី: ខ្ញុំនៅហ្នឹងបានពីរឆ្នាំ គិតខ្លួនឯងទៅ ។

ប៊ុនថន: ឆ្នាំ៨៣-៨៤-៨៥?

ធី: បាទ ។

ប៊ុនថន: ឆ្នាំ៨៥ពូផ្លាស់ទៅណាវិញ?

ធី: ខ្ញុំផ្លាស់មកនៅខាងក្រចេះ ។

ប៊ុនថន: នៅខាងក្រចេះវិញ?

ធី: បាទ!មកនៅលើគោកម្ដង ។

ប៊ុនថន: ៨៥ពេលវៀតណាមវាយខ្លាំងនៅទន្លេល្អោ?

ធី៖ អូស!ទន្លេល្ពៅខ្ញុំនៅហ្នឹងតើ ។

ប៊ុនថន៖ ពេលវៀតណាមវាយខ្លាំង?

ធី៖ បាទ ។

ប៊ុនថន៖ ពូនៅហ្នឹងអត់មានដកចេញទេ?

ធី៖ អត់ទេ អត់មានដកណា ។

ប៊ុនថន៖ ចឹងនៅវាយទប់ទល់ជាមួយវៀតណាមនៅហ្នឹង?

ធី៖ មានបានវាយអីទេ អត់ទេ ខ្ញុំនាំតែប្រពន្ធកូនរត់ហ្នឹង ។

ប៊ុនថន៖ ប្រពន្ធកូនពូរត់ទៅណា រត់ទៅ១០០១?

ធី៖ ខ្ញុំរត់ទៅស្រុកថៃ ។

ប៊ុនថន៖ ចុះពូ រត់ទៅជាមួយគាត់ដែរ?

ធី៖ ថាអោយប្រពន្ធរត់ទៅថៃនោះ មិនបានវាយយួនអីណាទេ ។

ប៊ុនថន៖ ចឹង៨៥ហ្នឹងរត់ទៅថៃ?

ធី៖ បាទ!កាំភ្លើងបោះក្រវែតចោលអស់រលីង ទុកតែកាំភ្លើងដាក់វ៉ាឡូប៉ុណ្ណឹងទេ ។

ប៊ុនថន៖ ពេលវៀតណាមវាយខ្លាំងនៅទន្លេល្ពៅហ្នឹងពូ?

ធី៖ ហ្នឹងហើយ ។

ប៊ុនថន៖ រត់ទៅថៃនៅម្តុំណាគេហៅអីវិញ?

ធី៖ គេហៅប៉ែតអ៊ូម ។

ប៊ុនថន៖ ប៉ែតអ៊ូមហ្នឹងនៅ១០០១-១០០២ឬ១០០៣?

ធី៖ នៅ១០០១ ។

ប៊ុនថន៖ កងពូរត់ទៅទាំងអស់?

ធី៖ រត់ទាំងអស់ អត់មាននៅតទេ ។

ប៊ុនថន៖ វរសេនាតូច៤០ហ្នឹងរត់ឡើងទាំងអស់?

ធី៖ រត់ទាំងអស់ ចុះបើមេរត់ហើយមិនទៅ អត់ទេ រត់ខ្ចិច អូសតែប្រពន្ធកូនប៉ុណ្ណោះទេ ។

ប៊ុនថន៖ ពូការឆ្នាំណា?

ធី៖ ការឆ្នាំ៨០ប៉ុន្មានទេ ភ្លេចអស់ហើយ ។

ប៊ុនថន៖ ចឹងពូអត់ចាំទេ?

ធី៖ អត់ចាំទេ ។

ប៊ុនថន៖ ហ្នឹងប្រពន្ធមុន?

ធី:     ប្រពន្ធអឹស ។

ប៊ុនថន:   ជាមួយមីងទេ រត់ទៅប៉ៃតអ៊ូម ។

ធី:     អាប្រពន្ធដើមអត់ទេ ហ្នឹងមុនទៀតនោះ ។

ប៊ុនថន:   ចឹងពូបានមីងឆ្នាំ៨៥ទេ?

ធី:     បាទ ។

ប៊ុនថន:   កាលហ្នឹងមានកូនហើយនៅ?

ធី:     មានតើ ថាពកូនរត់នោះខ្ញុំថា កូនមួយ ។

ប៊ុនថន:   ទៅនៅប៉ៃតអ៊ូមហ្នឹងបានយូរទេ បានប៉ុន្មានឆ្នាំ?

ធី:     នៅប៉ៃតអ៊ូមមួយឆ្នាំ បានចុះមកវិញ គេទុកនៅដីថៃ ដល់ហើយនាំគ្នាចុះមកវិញ មិនបានទៅបាញ់ទៅតប់អីទេ គិតតែពីរត់តែម្ដង ។

ប៊ុនថន:   ទៅនៅប៉ៃតអ៊ូមហ្នឹងការរស់នៅហូបចុកអីមានពីណាជួយឧបត្ថម្ភ?

ធី:     អង្គការអីណាទេ ។

ប៊ុនថន:   ចឹងអត់អីទេ យើងតទៀត ចឹងទៅប៉ៃតអ៊ូមខាងអង្គការគេជួយឧបត្ថម្ភ?

ធី:     បាទ ។

ប៊ុនថន:   ចឹងនៅបានមួយឆ្នាំពូចុះមកវិញ?

ធី:     បាទ ។

ប៊ុនថន:   ចុះមីងគាត់មកជាមួយពូទេ?

ធី:     ចុះមកទាំងអស់ ចុះមកទាំងអស់គ្នា ។

ប៊ុនថន:   ចុះមកនៅណា?

ធី:     ចុះមកនៅទឹកដីនេះ ។

ប៊ុនថន:   ចុះមកនេះវិញ?

ធី:     បាទ ។

ប៊ុនថន:   នៅភូមិសែនសំ ហ្នឹងតែម្ដង?

ធី:     បាទ ។

ប៊ុនថន:   ចឹងពូអត់ទៅនៅជីរំភូណាយជីរំអីទេ?

ធី:     ថាជីរំហ្នឹងឯងគេហៅជីរំភូណាយ ថៃហៅភូណាយ យើងថាភ្នំតូច ។

ប៊ុនថន:   ពូមានបាននៅហ្នឹងទេ?

ធី:     នៅហ្នឹងតើ ជីរំភូណាយហ្នឹង ។

ប៊ុនថន៖ ខ្មែរហៅភ្នំតូច?

ធី៖ បាទ! ខ្មែរហៅភ្នំតូច ថៃហៅភូណាយ ។

ប៊ុនថន៖ ចឹងពូចេញពី១០០១មកនៅភូណាយសិន ហើយបានមកនៅភូមិនេះ?

ធី៖ បាទ! ត្រូវហើយ ។

ប៊ុនថន៖ ចឹងពូធ្វើការនៅក្នុងកងពល៨១ដដែល?

ធី៖ បាទ ។

ប៊ុនថន៖ ជាយោធាដដែល?

ធី៖ បាទ ។

ប៊ុនថន៖ ពូមានចុះទៅធ្វើសកម្មភាពនៅខាងក្នុងវិញទេ?

ធី៖ អត់ទេ ។

ប៊ុនថន៖ ពូនៅខាងនេះ?

ធី៖ បាទ! មិនដែលទៅទេ ។

ប៊ុនថន៖ ពូបានកាន់វរៈដដែលឬមួយមានគេផ្លាស់ប្តូយ៉ាងម៉េចដែរ?

ធី៖ កាន់វរៈដដែលតែមិនដែលទៅ មិនដែលទៅទេ ។

ប៊ុនថន៖ ចឹងពូឈប់ធ្វើយោធាហើយឬយ៉ាងម៉េចដែរ?

ធី៖ នៅតែមិនដែលបានទៅ គេឲ្យនៅព្រំដែននេះ គេចុះមកនេះហើយ គេឲ្យនៅការពារតាមនេះ ៗចេះ មួយវរៈហ្នឹង ។

ប៊ុនថន៖ បាទ ។

ធី៖ គេថាឲ្យខ្ញុំទៅ គេថាគាងចាស់ហើយ ទៅមិនកើតទេ ឥឡូវយកកម្លាំងគាងទៅការពារ ។

ប៊ុនថន៖ ការពារមួយជួរអូរស្មាយនេះ?

ធី៖ បាទ ។

ប៊ុនថន៖ អូរស្មាយពីណាដល់ណា?

ធី៖ ពីត្រពាំងប្រាសាទទៅដល់ទួលគ្រួស ។

ប៊ុនថន៖ ចឹងពីត្រពាំងប្រាសាទដល់ទួលគ្រួស?

ធី៖ បាទ ។

ប៊ុនថន៖ ហ្នឹងកម្លាំងខាងពូ?

ធី៖ បាទ ។

ប៊ុនថន៖ ចុះពីភូណាយមកនៅនេះឆ្នាំណា?

ធី៖ ភ្លេចបាត់ហើយ ។

ប៊ុនថន៖ ចឹងពូមកនៅនេះជាប់រហូតឬមួយមានដកចេញតាំងពីចុះមកភូមិ?

ធី៖ នៅជាប់រហូត ។

ប៊ុនថន៖ តាំងពីសមាហរណ៍កម្ម?

ធី៖ បាទ!អត់មានទៅណាទេ កាប់ចម្ការធ្វើស្រែតែប៉ុណ្ណឹងទេ ។

ប៊ុនថន៖ រហូតដល់សមាហរណ៍កម្មពូនៅជាប់នៅនេះ?

ធី៖ បាទ ។

ប៊ុនថន៖ ចឹងក្រោយសមាហរណ៍កម្មហើយពូនៅធ្វើទាហានដដែល?

ធី៖ ធ្វើរហូត ។

ប៊ុនថន៖ ឥឡូវបច្ចុប្បន្ន?

ធី៖ ឥឡូវនេះអត់ទេ ខ្ញុំមិនបានធ្វើទេ ។

ប៊ុនថន៖ ចូលនិវត្តន៍ហើយ?

ធី៖ ចូលសោធន គេហៅសោធន ។

ប៊ុនថន៖ ចឹងមានប្រាប់ខបត្តម្ភរាល់ខែ?

ធី៖ រាល់ខែ ។

ប៊ុនថន៖ មួយខែបានប៉ុន្មានទៅ?

ធី៖ បាន១០០ ។

ប៊ុនថន៖ ចឹងបានច្រើនដែរ?

ធី៖ បាទ!បាន១០០ដែរ បាន៤០ម៉ឺន ។

ប៊ុនថន៖ ពូមានស្រែចម្ការអីមានទេ?

ធី៖ ខ្ញុំអត់មានទេ ។

ប៊ុនថន៖ យ៉ាងម៉េចបានជាអត់មាន?

ធី៖ អត់ ដីខ្ញុំមានតែមួយហាត់ហ្នឹង ។

ប៊ុនថន៖ មួយហាត់ហ្នឹងធ្វើស្រែឬមួយដាំដំឡូង?

ធី៖ ធ្វើមិនកើតទេ ចឹងបានថាក្រដល់កហើយ អាដីខ្ញុំខាងនោះពិបាកនិយាយណាស់ និយាយទៅវាឈ្លួសប្រកែកគ្នា ខ្ជិល អាមេភូមិអីណា ថាគេយកអីណា បានតែមួយហាត់ ។

ប៊ុនថន៖ ចឹងពូមានកូនប៉ុន្មាននាក់?

ធី៖ កូនខ្ញុំមានបួន ។

ប៊ុនថន៖ មានបានរៀនសូត្រទេពូ?

ធី៖ កំពង់ពេញហើយ ។

ប៊ុនថន៖ កូនទីមួយរៀនដល់ថ្នាក់ទីប៉ុន្មានហើយពូ?

ធី៖ កូនទី១អត់ទេ ។

ប៊ុនថន៖ អត់មានបានរៀនទេ?

ធី៖ អត់រៀន មែន ក៏ប៉ុន្តែសរសេរទៅមើលទៅដាច់ខ្ចិច អត់ចេះសរសេរ ។

ប៊ុនថន៖ ចឹងអត់ចេះសរសេរតែអានរួច?

ធី៖ អានរួច ឡើងរូបណេ្តាយ ។

ប៊ុនថន៖ ចឹងកូនទី២?

ធី៖ កូនទីប្រុសម៉ាសេរីរបស់វា ។

ប៊ុនថន៖ តែនៅរៀនទេ?

ធី៖ អត់ទេ ឈប់ហើយយកប្រពន្ធហើយ អាកូនទី៣កំពង់រៀន អាកូនទី១កំពង់រៀនទៀត ។

ប៊ុនថន៖ រៀនសាលាបឋមសិក្សា?

ធី៖ បាទ! គេឲ្យទៅរៀននោះ តែខ្ញុំហ្នឹងមានខ្វាំងពេក មានខ្វាំងពេកអត់មានកង់ជិះ សើច...។

ប៊ុនថន៖ បាទ ។

ធី៖ គេឲ្យទៅនោះទេ គ្រូទេ ចាងហ្វាងគេឲ្យទៅនោះ ទៅអនុវិទ្យាល័យនៅត្រពាំងប្រាសាទនោះ អនុវិទ្យាល័យហ៊ុន សែន សម្តេចដែកជោ ។

ប៊ុនថន៖ ចឹងពូធ្លាប់ឆ្លងកាត់របបតស៊ូអីចឹងពូមានដែលនិយាយប្រាប់កូនចៅ?

ធី៖ ប្រាប់តើ ថាកូនអើយខ្ញុំពីដើមលំបាកណាស់ មិនមែនស្រួលដូចពួកឯងឥឡូវនេះទេ សូម្បីតែស្បែកជើងក៏អត់មានពាក់ទៀត តស៊ូណាស់ ខែប្រាំងអីក៏ដោយទឹកអត់មានផឹក ខំប្រឹងហើយដល់ចឹងពួកឯងឥឡូវនេះស្អី គ្រាន់ចុះពីលើផ្ទះទឹកប្រវែងហ្នឹងអត់មានដងអី ទៅណាសុទ្ធតែម៉ូតូសុទ្ធឡានអី ឆាប់ហើយ ។

ប៊ុនថន៖ កូនពូមានជឿងទេ ពូនិយាយចឹង?

ធី៖ ជឿ ។

ប៊ុនថន៖ ជឿដែរ?

ធី៖ បាទ! ជឿថា ឪអើយពីដើមលំបាកណាស់ ។

ប៊ុនថន៖ ចឹងពូមានវត្តមានលោកអី ទើបកើតក្រោយមកទេ?

ធី៖ កើតមុន ។

ប៊ុនថន: កើតមុន?

ធី: វត្តលោកហ្នឹង ។

ប៊ុនថន: បាទ ។

ធី: វត្តលោកកើតក្រោយ យើងសង់ក្រោយ ។

ប៊ុនថន: ចឹងពីមុនមកអត់មានទេ?

ធី: អត់មានទេ ។

ប៊ុនថន: ចឹងពីមុនមកពូអត់មានបានទៅវត្តទេ?

ធី: អត់ទេ ។

ប៊ុនថន: ចឹងក្រោយមកពូមានបានទៅវត្តទេ?

ធី: ទៅ ។

ប៊ុនថន: ពូមកពីស្រុកឆ្ងាយពីស៊ីងត្រែងអី មកចឹងពូរាប់អានជាមួយអ្នកជិតខាងយ៉ាងម៉េចដែរ?

ធី: អត់មានអីទេ គេរាក់ទាក់ ថ្ងៃនេះអត់មានឃើញមនុស្ស បើរាល់ថ្ងៃនោះផ្ទះខ្ញុំចង្អៀតមកឡើងពេញ គេមកលេងស្អីនេះគេនោះ ពេញផ្ទះ តែបន្តិចទៀតមកឥឡូវហើយ ។

ប៊ុនថន: រាប់អានជាមួយអ្នកជិតខាងអីហ្នឹង?

ធី: បាទ!មិនថាចាស់មិនថាក្មេងទេ បើខ្ញុំនិយាយក សួរតែយាយខ្ញុំទៅ ។

ប៊ុនថន: ចឹងខ្ញុំដូចជាអស់អីសួរពូហើយ ពូមានអីចង់ថែមទៀតទេ?

ធី: ខ្ញុំមិនចង់ថែមអីទេ ខ្ញុំចង់ថាប្អូនមកសម្ភាសចឹង ក៏ពូចង់ជូនពរតែប៉ុណ្ណឹងទេ ។

ប៊ុនថន: បាទ!ចឹងអរគុណពូច្រើន ។

ធី: បាទ!ជូនពរឲ្យមានសុខភាពល្អ ។

ប៊ុនថន: បាទ ។

**ចប់**